ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ : ...១៣៥៧... អ.រតន.

រាជធានីភ្នំពេញ, ថ្ងៃទី ...២២... ខែ ...៧... ឆ្នាំ ២០០៩

# សេចក្តីណែនាំ
## ស្តីពី
## កិច្ចបញ្ជិកាចំណូលថវិកាពីកម្រៃការប្រាក់ដែលបានទទួលពីធនាគារអេស៊ីលីដា ភីអិលស៊ី សាខាខេត្តបន្ទាយមានជ័យ និង សាខាខេត្តកណ្តាល

*****

យោងអនុស្សរណៈយោគយល់គ្នារវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ធនាគារអេស៊ីលីដា ភីអិលស៊ី ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ ។

ដើម្បីអោយមានលក្ខណៈងាយស្រួលលើការអនុវត្តប្រតិបត្តិការចំណូលថវិកា ដែលបានពីកម្រៃការប្រាក់ លើគណនីចរន្ត ដែលបើកនៅធនាគារអេស៊ីលីដា ភីអិលស៊ី សាខាខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាល អគ្គនាយកដ្ឋានរតនាគារជាតិសូមចេញសេចក្តីណែនាំអំពីនីតិវិធីកត់ត្រាដូចមានខ្លឹមសារខាងក្រោមនេះ :

### I- កិច្ចបញ្ជិកានៅរតនាគារខេត្ត :

**១-**នៅថ្ងៃដំណាច់ខែនីមួយៗ ធនាគារអេស៊ីលីដា ភីអិលស៊ី សាខាខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាលនឹងធ្វើការគណនារកចំនួនទឹកប្រាក់កម្រៃការប្រាក់នៃគណនីចរន្តទាំង ៣ របស់រតនាគារខេត្ត ។

**២-**នៅដើមខែបន្ទាប់ សាខាធនាគារអេស៊ីលីដានឹងកត់ត្រាទឹកប្រាក់កម្រៃការប្រាក់ ទៅក្នុងគណនីចរន្ត ដែលពាក់ព័ន្ធ រួចប្រគល់ប្រកាសឥណទានជូនទៅរតនាគារខេត្ត ។ រតនាគារខេត្តត្រូវធ្វើលិខិតជូនដំណឹង ឥណពន្ធ និង ប្រកាសឥណទាន ផ្ទេរទឹកប្រាក់កម្រៃការប្រាក់មកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយកត់ត្រា :

ឥណពន្ធ គណនី ចរន្តសម្រាប់ចំណូល ( លេខ 517.1.2.01 )

ឥណទាន គណនី ទំនាក់ទំនងរវាងរតនាគារខេត្ត និងអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិបត្តិការផ្សេងៗ ( លេខ 458.2.4)

ឥណពន្ធ គណនី ចរន្តសម្រាប់ចំណាយ ( លេខ 517.1.2.02 )

ឥណទាន គណនី ទំនាក់ទំនងរវាងរតនាគារខេត្ត និងអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិបត្តិការផ្សេងៗ

( លេខ 458.2.4 ) និង

ឥណពន្ធ គណនី ចរន្តសម្រាប់ចំណូល ចំណាយ ឃុំ សង្កាត់ ( លេខ 517.1.2.03 )

ឥណទាន គណនី ទំនាក់ទំនងរវាងរតនាគារខេត្ត និងអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិបត្តិការផ្សេងៗ ( លេខ 458.2.4 ) ។

**៣-** អនុញ្ញាតអោយធនាគារអេស៊ីលីដាភីអិលស៊ី សាខាខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល ផ្ទេរប្រាក់កម្រៃការប្រាក់ពីគណនីចរន្តចរន្តសម្រាប់ចំណាយ និងគណនីចរន្តសម្រាប់ចំណូល- ចំណាយរបស់ឃុំ សង្កាត់ ទៅគណនី ចរន្តសម្រាប់ចំណូល ដោយស្វ័យប្រវត្តិនៅរៀងរាល់ដើមខែបន្ទាប់ ។

**៤-** នៅពេលទទួលបានប្រកាសឥណពន្ធ និងប្រកាសឥណទានពីសាខាធនាគារអេស៊ីលីដា រតនាគារខេត្តត្រូវធ្វើលិខិតជូនដំណឹង ឥណទាន រួចកត់ត្រា :

ឥណពន្ធ គណនី ចរន្ត សម្រាប់ចំណូល ( លេខ 517.1.2.01 )

ឥណទាន គណនី ចរន្ត សម្រាប់ចំណាយ ( លេខ 517.1.2.02 ) និង

ឥណពន្ធ គណនី ចរន្ត សម្រាប់ចំណូល ( លេខ 517.1.2.01 )

ឥណទាន គណនីចរន្ត សម្រាប់ចំណូល ចំណាយ ឃុំ សង្កាត់ ( លេខ 517.1.2.03 ) ។

**បញ្ជាក់ :** សមតុល្យនៃគណនីចរន្ត សម្រាប់ចំណូល នឹងត្រូវផ្ទេរទៅគណនី ចរន្តរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារជាតិ នៃកម្ពុជានៅចុងថ្ងៃនីមួយៗ នៅវេលាម៉ោង ១៥ និង ៣០ នាទី ។ ចំនួនប្រាក់ចំណូលរបស់រតនាគារខេត្ត ដែលសាខាធនាគារអេស៊ីលីដាបានទទួលក្រោយពីម៉ោង ១៥ និង ៣០ នាទី ត្រូវបានកត់ត្រា ជាប្រតិបត្តិការនៅក្នុងថ្ងៃដដែល ហើយត្រូវធ្វើការផ្ទេរជាមួយនឹងប្រតិបត្តិការនៅថ្ងៃបន្ទាប់ ។

### ***II- កិច្ចបញ្ជិកានៅអគ្គនាយកដ្ឋានរតនាគារជាតិ :***

**១-** ក្រោយពេលទទួលបានប្រកាសឥណទាន និង លិខិតជូនដំណឹងឥណពន្ធ ស្តីពីប្រាក់កំរៃការប្រាក់ប្រចាំខែ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវធ្វើលិខិតជូនដំណឹងឥណពន្ធ និង ឥណទាន រួចកត់ត្រា :

ឥណពន្ធ គណនី ទំនាក់ទំនងរវាងអគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគារខេត្ត ប្រតិបត្តិការផ្សេងៗ ( លេខ 458.1.4)

ឥណទាន គណនី ចំណូលថវិកា ការប្រាក់ ( លេខ 761 ) ។

**២-** ក្រោយពេលទទួលបានប្រកាសឥណទាន ពីធនាគារជាតិនៃកម្ពុជា ស្តីពីការទទួលសាច់ប្រាក់ផ្ទេរពីរតនាគារខេត្ត អគ្គនាយកដ្ឋានរតនាគារជាតិត្រូវធ្វើ លិខិតជូនដំណឹងឥណពន្ធ ឥណទាន រួចកត់ត្រា :

ឥណពន្ធ គណនី ចរន្តនៅធនាគារជាតិ នៃកម្ពុជា ( លេខ 510.1)

ឥណទាន គណនី សាច់ប្រាក់បានទទួលពីខេត្តរង់ចាំនិយ័ត្តកម្ម ( លេខ 470.3 ) ។

៣-ក្រោយពេលទទួលបានប្រកាសឥណពន្ធ ពីរតនាគាខេត្ត ស្តីពីការផ្ទេរសាច់ប្រាក់ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវធ្វើ លិខិតជូនដំណឹងឥណពន្ធ រួចកត់ត្រា :

ឥណពន្ធ គណនី សាច់ប្រាក់បានទទួលពីខេត្តរង់ចាំនិយ័ត្តកម្ម ( លេខ 470.3 )

ឥណទាន គណនី ទំនាក់ទំនងរវាងអគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគារខេត្ត ប្រតិបត្តិការផ្ទេរប្រាក់ ( លេខ 458.1.3) ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានគ្រប់នាយកដ្ឋានពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានរតនាគារជាតិ លោកប្រធានរតនាគារខេត្តបន្ទាយមានជ័យ និងលោកប្រធានរតនាគារខេត្តកណ្តាល ចាត់ចែងការអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។/.

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយករងស្តីទីអគ្គនាយកដ្ឋានរតនាគារជាតិ

ជិន ឃុនឌ

**ចម្លងជូន**

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លេខាធិការដ្ឋាននៃគណ:កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:
- នាយកដ្ឋានថវិកា
- អង្គភាពគ្រប់គ្រងសាច់ប្រាក់

  " ដើម្បីជូនជ្រាប "
- រតនាគារខេត្តបន្ទាយមានជ័យ
- រតនាគារខេត្តខេត្តកណ្តាល
- ធនាគារអេស៊ីលីដា ភីអិលស៊ី

  "ដើម្បីសហការអនុវត្ត "
- ឯកសារ-កាលប្បវត្តិ